សួស្តី សហគមន៍សាលារៀននិងបុគ្គលិកនៅឡុងប៊ីច

ការចាប់ផ្តើមឆ្នាំសិក្សាថ្មី មានភាពខុសប្លែកយ៉ាងខ្លាំងសម្រាប់យើងទាំងអស់គ្នា នៅក្នុងសហគមន៍ឡុងប៊ីច។ ចំពោះបុគ្គលិក មិនថាឡើយតួនាទីរបស់លោកអ្នកជាអ្វីក៏ដោយ អ្នកត្រូវតែមានភាពបត់បែន ភាពច្នៃប្រឌិត និងភាពអត់ធ្មត់។ ចំពោះក្រុមគ្រួសារសិស្ស អ្នកត្រូវជួយគាំទ្រកូនរបស់លោកអ្នកតាមរបៀបថ្មីផ្សេងៗ ចែករំលែកពេលវេលាធ្វើការងារ ដើម្បីមកជួយក្នុងការរៀនសូត្ររបស់កូន ហើយតស៊ូនឹងការរស់នៅតទៅទៀត នៅក្នុងស្ថានភាពរោគរាតត្បាតជាសាកលនេះ។

ថ្ងៃនេះខ្ញុំសូមជំរាបប្រាប់អំពីការសម្រេចចិត្តរបស់ក្រសួងអប់រំយើង ក្នុងការបន្តការរៀនពីផ្ទះ រហូតពេញមួយឆមាសទីមួយនេះ ដែលនឹងបន្តទៅដល់ថ្ងៃទី២៨ខែមករា។ ប៉ុន្តែ ខ្ញុំមិនគ្រាន់តែចង់ប្រាប់លោកអ្នក តែប៉ុនហ្នឹងទេ ខ្ញុំចង់ផ្តល់ព័ត៌មានបន្ថែមទៀត ដែលជាដើមហេតុនៃការសម្រេចចិត្តនេះ។

អ្វីមួយដែលជារឿងពិបាកបំផុតនៅក្នុងស្ថានភាពរោគរាតត្បាតនេះគឺយើងមិនអាចមើលឃើញបានថាពេលណាវានឹងចប់។ អារម្មណ៏ដែលមិនអាចដឹងនេះ គឺពិបាកដល់យើងទាំងអស់គ្នា ខណៈដែលយើង ប្រឹងប្រែងធ្វើការសម្រេចចិត្ត សម្រាប់ផលប្រយោជន៍ដល់សិស្សានុសិស្សរបស់យើង ស្របពេលជាមួយគ្នាដែលយើងខិតខំការពារសុខភាពនិងសុវត្ថិភាពរបស់អ្នករាល់គ្នា។

នៅក្នុងប៉ុន្មានខែនារដូវក្តៅកន្លងទៅនេះ និងរហូតមកដល់ពេលចាប់ផ្តើមឆ្នាំសិក្សាថ្មី យើងបានបន្តបើកការជួបប្រជុំជារឿយៗ ជាមួយក្រសួងសុខាភិបាលក្រុងឡុងប៊ីច ចូលរួមក្នុងការធ្វើបច្ចុប្បន្នភាពជាមួយក្រសួងសុខាភិបាលខោនធីឡូសអ៊ិនជើលេស ហើយនិងជាមួយការណែនាំរបស់គេ យើងបានចម្រាញ់ពិធីការរបស់យើងសម្រាប់ឆ្លើយតបនឹងកូវិឌ១៩។ ដោយសារតែ យើងបានបើកការិយាល័យក្រសួងអប់រំ ហើយធ្វើការនៅសាលារៀនក្នុងរយៈពេលនៃរដូវក្តៅនេះ យើងបានត្រូវឆ្លើយតបទៅនឹងកូវិឌនៅកន្លែងការងារ។ រហូតទាល់តែមានថ្នាំវ៉ាក់សាំងបង្ការរោគ គ្រប់ក្រសួងនិងកន្លែងការងារ ត្រូវតែរៀបចំប្រុងប្រៀប ដើម្បីឆ្លើយតបទៅនឹងកូវិឌ ជាជាងការគិតថា កូវិឌនឹងមិនអាចប៉ះពាល់ដល់សហគមន៍យើងបានឡើយ។

ដូចដែលលោកអ្នកអាចបានដឹងមកហើយថា ទិន្នន័យសុខភាពនៅក្នុងខោនធីឡូសអ៊ិនជើលេស បានប្រសើរឡើងជាទូទៅ ថ្វីបើយើងនៅមិនទាន់បានដកចេញពីបញ្ជីឃ្លាំមើលរបស់រដ្ឋក៏ដោយ។ នេះគឺមានន័យថា ក្រសួងអប់រំឡុងប៊ីច នៅមិនទាន់បានអនុញ្ញាតឱ្យបើកសាលាសម្រាប់ទៅរៀននៅក្នុងថ្នាក់វិញ នៅឡើយទេ។

ដើម្បីឱ្យគេអាចដកខោនធីចេញពីបញ្ជីឃ្លាំមើលបានរបស់រដ្ឋបាន គឺ

- ខោនធីត្រូវតែបង្ហាញថាមានមនុស្សតិចជាង១០០លើ១០០០០០នាក់ ដែលធ្វើតេស មានវិជ្ជមាននៃវីរុស។
- អត្រាដែលមនុស្សបានធ្វើតែសវិជ្ជមាននៃវីរុសត្រូវតែនៅក្រោម៨ភាគរយ។
- ចំនួនមនុស្សដែលសម្រាកព្យបាលនៅពេទ្យមិនត្រូវកើនឡើងលើសពី១០នាក់ក្នុងកំឡុងរយៈពេល៣ថ្ងៃ។
- មន្ទីរពេទ្យត្រូវមានគ្រែនៅសល់២០ភាគសម្រាប់ព្យាលបាលអ្នកឈឺធ្ងន់ ហើយនិងម៉ាស៊ីន ជួយឱ្យដកដង្ហើម នៅសល់ចំនួន២៥ភាគរយ។

ទិន្នន័យសុខភាពនៅក្នុងឡុងប៊ីចបានស្ថិតស្ថេរ ប៉ុន្តែនៅតែខ្ពស់សម្រាប់ឱ្យសិស្សអាចទៅរៀននៅសាលាវិញបាន ដូច្នេះការសម្រេចចិត្តរបស់យោះងក្នុងការបន្តពេលរៀននៅផ្ទះ គឺយោងទៅតាមការពីគ្រោះជាមួយមន្ត្រីសុខភាព។ យើងនឹងបន្តគ្រោងសម្រាប់ការអនុញ្ញាត ឱ្យទៅសាលាវិញ ជាដំណាក់ៗ សម្រាប់សេវាកម្មគាំទ្រសិស្សខ្លះ និងការរៀននៅសាលាខ្លះ មុនចុងឆមាសនេះ។ ដូចគ្នានឹងផែនការទាំងអស់ក្នុងស្ថានភាពរោគរាតត្បាត ផែនការទាំង នេះត្រូវការការតាមដានមើលយ៉ាងជិតដល់និងត្រូវការភាពអាចបត់បែន ដើម្បីដូរទិសដៅ យោងតាមស្ថានភាពនៅក្នុងសហគមន៍។

ខ្ញុំត្រូវបានសមាជិកខ្លះក្នុងសហគមន៍សួរ  ថាហេតុអ្វីបានជាមិនបើកសាលារៀន ព្រោះយោលទៅតាមប្រភពខ្លះ សិស្សមិនងាយឆ្លងរោគកូវិឌទេ។ ខណៈដែលចម្លើយវាស្មុគស្មាញ ជាងការឆ្លើយតបងាយៗ និយាយឱ្យខ្លីគឺថា សាលារៀនមិនអាចមានដំណើរការបានដោយ គ្មានមនុស្សចាស់ច្រើនធ្វើការ ហើយនៅពេលដែលយើងបើកឱ្យមានមនុស្សចាស់និងសិស្ស ច្រើនគ្នានៅកន្លែងតែមួយ វាមានឱកាសខ្ពស់ក្នុងការចម្លងរោគឆ្លង។ ថែមពីនោះទៀត ដោយ គ្មានថ្នាំវ៉ាក់សាំង កូវិឌ១៩នឹងបន្តរាលដាលក្នុងសហគមន៍យើង យើងជឿថា ការទប់ស្កាត់មិនឱ្យមានការបើកហើយបិទ បើកហើយបិទសាលា គឺជាវិធានការប្រសើរបំផុត ដើម្បីកុំឱ្យរំខានដល់ការរៀនសូត្ររបស់សិស្សយើង ហើយអាចអនុញ្ញាតឱ្យមាតាបិតាសិស្សរៀបចំគ្រោងសម្រាប់សប្តាហ៍និងខែទៅថ្ងៃមុខ។

មានតែការសម្រេចមួយគត់ក្នុងរយៈពេល៦ខែកន្លងមកនេះ ដែលធ្វើឱ្យយើងមានអារម្មណ៍ថាជាការងាយស្រួល។ គឺការសម្រេចផ្តល់អាហារពេលព្រឹក ថ្ងៃត្រង់ និងពេលល្ងាចនៅសាលាដើម្បីបញ្ជាក់ថាសិស្សយើងមានអាហារញុំា ទោះបីជាសារៀនបិទមិនបង្រៀនក៏  ដោយ។

យើងនឹងបន្តផ្តល់ព័ត៌មានថ្មីៗដល់លោកអ្នកនៅថ្ងៃខាងមុខនេះ ជាពិសេសអំពីផែនការអ្វី ដែលយើងអាចផ្តល់សេវាកម្មនិងបើកសាលារៀនវិញ ជាដំណាក់ៗ។

សប្តាហ៍កន្លងទៅនេះខ្ញុំបានទៅមើលសាលារៀនមួយចំនួនហើយមានការពេញចិត្តដោយឃើញបុគ្គលិកសាលព្យាយាមភ្ជាប់ជាមួយសិស្សហើយផ្តល់ការយកចិត្តទុកដាក់ដែលសិស្សត្រូវការនៅក្នុងពេលពិបាកនេះនៅក្នុងសហគមន៍យើង។ គ្រូបង្រៀនរវល់មមារញឹកស្វាគមន៍សិស្សនៅក្នុងរៀន Canvas ថ្មី ដំបូងគឺយកចិត្តទុកដាក់ធ្វើឱ្យមានអារម្មណ៍បន្តភ្ជាប់និងអាចរៀនសូត្របាន។ បុគ្គលិកសាលាបានធ្វើការទាក់ទងជាមួយគ្រួសារដើម្បីផ្តល់ក្រុមប៊ុគ និងកន្លែងប្រើអ៊ិនធឺនែត ហើយស្វែងរកមើលសិស្សណាដែលមិនទាន់បានបង្ហាញខ្លួននៅ សាលា។ ខណៈដែលយើងរីករាយថាចំនួនវត្តមានតាមអនឡាញកំពុងតែកើនឡើងជិតដល់ចំនួនដែលសិស្សទៅរៀននៅសាលាតាមធម្មតា យើងនៅតែប្តេជ្ញាធ្វើយ៉ាងណា ឱ្យសិស្សរាល់គ្នា មានលទ្ធភាពរៀនតាមអនឡាញបាន។ ការខ្នះខ្នែងទាំងនេះ ធ្វើឱ្យមានភាពប្រសើរឡើងសំរាប់សិស្សយើងនិងសហគមន៍យើងទាំងមូល។

ខ្ញុំដឹងយ៉ាងច្បាស់ថា ថ្ងៃទៅខាងមុខនេះនឹងមានភាពពិបាកដល់យើងជាសហគមន៍មួយ។ ខ្ញុំក៏ដឹងផងដែរថា វាជាលទ្ធភាពរបស់យើងក្នុងការរួបរួមគ្នា គាំទ្រគ្នាទៅវិញទៅមក ដែលនឹងនាំយើងទៅដល់ត្រើយម្ខាងនៃការរាតត្បាតនេះ។ ខ្ញុំនឹងបន្តមានសេចក្តីសង្ឃឹមដល់ពេលប្រសើរឡើងក្នុងក្រសួងអប់រំឡុងប៊ីច នៅពេលដែលយើងអាចវិលត្រឡប់ទៅសាលារៀនជាទីស្រឡាញ់របស់យើង ដែលភាពអស្ចារ្យនៃការបង្ហាត់បង្រៀននិងការរៀនសូត្រអាចជាថ្មីម្តងទៀត កើតមានឡើងវិញនៅក្នុងគ្រប់ថ្នាក់រៀនទូទាំងទីក្រុងរបស់យើង។